អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងដឹកអីវ៉ាន់**

**ចិត្តចលភាព** ៖ បំណិនចលនាតូចៈ

ការហ្វឹកហាត់បង្កើតកម្លាំងនិងសម្របសម្រួលរវាងចលនាសាច់ដុំដៃនិងសាច់ដុំភ្នែកៈ

**វិទ្យាសាស្រ្ត** ៖ ប្រតិបត្តិដោយសុវត្ថិភាពៈ ការយល់ដឹងពីការប្រតិបត្តិខ្លួន ដើម្បីសម្រាប់សុវត្ថិភាពៈ

**បុរេគណិត** ៖ បរិមាណនិងចំនួនៈ ស្គាល់នឹងយល់លេខតាងនិងការគណនាលេខសាមញ្ញៈ

ទំហំនិងពណ៌ៈ ចំណាត់ថ្នាក់ក្រុមនិងលំដាប់លំដោយៈ

**គោលបំណង**

**ចិត្តចលភាព** ៖ បំណិនសម្បទាៈ

កំណត់ចំណុចគោលដៅនៃចលនាដៃដោយការទប់លំនឹងនិងសម្របសម្រួលទៅនឹងភ្នែកក្នុងពេលធ្វើអ្វីមួយឬលេងល្បែងបានរឹងមាំល្អ។

**វិទ្យាសាស្រ្ត** ៖ បំណិនសម្បទាៈ ប្រាប់បានពីវត្ថុដែលបណ្តាលឱ្យមានគ្រោះថ្នាក់ដូចជាៈ ភ្លើងអគ្គីសនី ថ្នាំសម្លាប់សត្វល្អិត ថ្នាំពេទ្យ ស្លាកសញ្ញាមីន ស្លាកសញ្ញាចរាចរណ៍ វត្ថុមុតស្រួច ទឹកពាង និងទឹកស្រះ។

**បុរេគណិត** ៖ បំណិនសម្បទាៈ រាប់ចំនួនលេខ និងយល់ន័យពី១ដល់៣០ឬលើសពីនេះ។

បំណិនសម្បទាៈ រៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**កម្រិតសិក្សា** ៖ មធ្យមនិងខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ដុំឈើ ឬ ដុំថ្ម ឬសម្ភារដែលមានអាចប្រើប្រាស់សម្រាប់ធ្វើជាទំនិញបាន (សម្ភារតូចៗ)។

ក្រដាសសន្លឹកកិច្ចការដែលមានជារូបភាពឡានដឹកទំនិញប្រាំមួយប្រភេទ (អ៊ុតឱ្យបានស្អាត) គ្រាប់ឡុកឡាក់ចំនួន។

**ការរៀបចំ** ៖ ត្រៀមសម្ភារដែលត្រូវលេងជាក្នុងល្បែងសកម្មភាពនេះឱ្យបានគ្រប់ជ្រុងជ្រោយ និងត្រូវច្បាស់ពីរបៀបលេងល្បែងឱ្យបានច្បាស់ជាមុនសិន មុននឹងនាំកុមារលេង។

**សេចក្តីណែនាំ** ៖

1. សួរកុមារថា កូនៗមានស្គាល់ឡានដឹកទំនិញអត់?

2. កុមារគួរតែស្គាល់ប្រភេទឡាននីមួយៗជាមុនសិន និងគ្រូគួរតែប្រាប់ពីសុវត្ថិភាពនិងគ្រោះថ្នាក់ឱ្យកុមារបានយល់និងដឹងពីរបៀបប្រុងប្រយ័ត្នជាមុនសិនដែរ។
3. ប្រាប់កុមារពីរបៀបល្បែងសកម្មភាពមួយនេះឱ្យច្បាស់ជាមុនសិន៖
    - មួយក្រុមមានសមាជិក៦នាក់
    - ក្នុង១ក្រុមមានក្រដាសន្លឹករូបភាពឡាន៦ដែរ គ្រាប់ឡុកឡាក់ចំនួនមួយគ្រាប់ និងវត្ថុជាសម្ភារដែលទុកជាអីវ៉ាន់ មួយចំនួនដែលបានរៀបចំសម្រាប់លេងល្បែងនេះ។
    - សមាជិកក្នុងក្រុមនីមួយៗមានសន្លឹកកិច្ចការរូបភាពម្នាក់១ (ក្នុងរូបឡានមានចំនួនគ្រាប់ឡុកឡាក់ពីមួយដល់ប្រាំមួយ)
    - ដាក់អីវ៉ាន់នៅចំកណ្តាលវង់ ដោយសមាជិក្រុមអង្គុយជារង្វង់។
    - សមាជិកណាម្នាក់ត្រូវបោះគ្រាប់ឡុកឡាក់មុនគេ បន្ទាប់គ្រាប់ត្រូវបោះម្នាក់១ដង។
    - ពេលគ្រាប់ឡុកឡាក់រមៀលបានចំនួនប៉ុន្មាន អ្នកដែលមានឡានដែលមានចំនួនប៉ុណ្ណឹងត្រូវយកវត្ថុមួយ (អីវ៉ាន់) ដាក់ចូលឡានរបស់ខ្លួនចំនួន១។
    - ការរមៀលគ្រាប់ឡុកឡាក់នេះ យើងអាចកំណត់ត្រឹមតែ១០ ឬ១៥ដង ទៅតាមការកំណត់របស់អ្នកលេង ឬគ្រូ។
    - នៅពេលដែលគ្រប់ចំនួនដងដែលរមៀលគ្រាប់ឡុកឡាក់ហើយ ត្រូវរាប់ចំអីវ៉ាន់ ថាតើឡានមួយណាដែលមានអីវ៉ាន់ច្រើនជាងគេ ជាការស្រេច។

ចំណាំ៖

យើងអាចលេងបានច្រើនប្រភេទ មិនមែនតែដូចក្នុងវិធីលេងនេះទេ ព្រោះនេះគ្រាន់តែជាការឧទាហរណ៍សម្រាប់ការលេងមួយប្រភេទតែប៉ុណ្ណោះ។